ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
លេខៈ ១០៩០ អ គ រ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨

# សេចក្តីណែនាំ
# ស្តីពី
# ការអនុវត្តនីតិវិធីនៃការឆ្លងកាត់គយ

អនុលោមតាមបញ្ញត្តិប្រការ ៤ នៃប្រកាសលេខ ៩០៨ សហវ.ប្រក ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការឆ្លងកាត់គយ កន្លងមកទីចាត់ការគយ និងរដ្ឋាករបានចេញនូវសេចក្តីណែនាំ លេខ ៧៩០ គរ ចុះថ្ងៃទី ២៨.ខែ សីហា ឆ្នាំ ២០០៨ ស្តីពីនីតិវិធីនៃការឆ្លងកាត់គយ ដើម្បីទុកជាបទបញ្ញត្តិមូលដ្ឋានពាក់ព័ន្ធនឹងការបំពេញបែបបទគយលើការដឹកជញ្ជូនទំនិញក្រោមនីតិវិធីនៃការឆ្លងកាត់គយ។ ទន្ទឹមនឹងនេះដើម្បីជម្រុញឱ្យការអនុវត្តនីតិវិធីនៃការឆ្លងកាត់គយប្រព្រឹត្តទៅបានល្អតាមស្តង់ដារល្អបំផុតជាអន្តរជាតិ និងមានភាពគ្រប់ដណ្តប់លើទិដ្ឋភាពផ្សេងទៀតនោះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាសូមធ្វើការណែនាំដូចខាងក្រោម :

១. ការអនុវត្តនីតិវិធីតាមបញ្ញត្តិនៃសេចក្តីណែនាំលេខ ៧៩០ គរ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ : អនុវត្តចំពោះតែការដឹកជញ្ជូនទំនិញក្រោមនីតិវិធីនៃការឆ្លងកាត់ជាអន្តរជាតិ (International Transit) ស្របតាមបញ្ញត្តិកថាខណ្ឌទី ១ ហើយជាការដឹកជញ្ជូនទំនិញឆ្លងកាត់ពីការិយាល័យគយមាត់ច្រកព្រំដែនចូលទៅកាន់ការិយាល័យគយមាត់ច្រកព្រំដែនចេញប៉ុណ្ណោះ។

ចំពោះការដឹកជញ្ជូនទំនិញក្រោមរបបឆ្លងកាត់ជាអន្តរជាតិ ជាទូទៅប្រតិបត្តិករនីតិវិធីនៃការឆ្លងកាត់គយអាចជ្រើសរើសយកការបំពេញបែបបទគយតាមនីតិវិធីខាងលើនេះនាពេលដឹកជញ្ជូនឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ឬក៏អាចអនុវត្តតាមបញ្ញត្តិនៃបណ្តាកិច្ចព្រមព្រៀងអន្តរជាតិនានាក្នុងតំបន់ ទោះជាលក្ខណៈទ្វេភាគី ឬពហុភាគីក្តី ដែលព្រះរាជាណាចក្រកម្ពុជាបានចូលរួមជាភាគីហត្ថលេខី ។

២. ការអនុវត្តនីតិវិធីគយពាក់ព័ន្ធនឹងការឆ្លងកាត់ជាតិ ( National Transit ) តាមបញ្ញត្តិកថាខណ្ឌទី ២ ប្រការ ២ នៃប្រកាសស្តីពីការឆ្លងកាត់គយ : ត្រូវអនុវត្តតាមសេចក្តីណែនាំលេខ ៧៩០ គរ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ ដូចមានចែងខាងលើដោយគ្រាន់តែកែសម្រួលមួយចំនួនដូចតទៅ ៖

អាស័យដ្ឋានៈ លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ/ទូរសារៈ (៨៥៥-២៣) ២១៤ ០៦៥ / ៧២៤ ១៥៧ / ២១២ ៥៥៧ E-mail: customs@camnet.com.kh

ក. នីតិវិធីគយនៅមាត់ច្រកចូល និងមាត់ច្រកចេញ ដូចមានចែងក្នុងសេចក្តីណែនាំលេខ ៧៩០ គរ ខាងលើត្រូវបានកែសម្រួលទៅជា នីតិវិធីគយនៅការិយាល័យគយចេញដំណើរ (Customs Office of Departure) និងការិយាល័យគយគម្យដ្ឋាន (Customs Office of Destination) វិញ ។

ខ. ត្រាបញ្ជាក់លើប្រតិវេទន៍គយឆ្លងកាត់របស់មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចនាការិយាល័យគយចេញដំណើរសម្រាប់ការដឹកជញ្ជូន ក្រោមនីតិវិធីនៃការឆ្លងកាត់ជាតិដូចនេះ ត្រូវបានកំណត់បន្ថែមដូចគម្រូភ្ជាប់ជាមួយនេះ ។

៣. មុខទំនិញមួយចំនួន ដែលមិនត្រូវបានអនុញ្ញាតជាបណ្តោះអាសន្នឱ្យដឹកជញ្ជូនក្រោមរបបគយឆ្លងកាត់មាន ៖

ក. បណ្តាទំនិញដែលស្ថិតក្នុងបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់តាមបញ្ញត្តិនៃអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលជាប់ប្រព្រឹត្តិកម្មហាមឃាត់ដាច់ខាត (ប្រព្រឹត្តិកម្មលេខ ៤ លេខ ៥ និងលេខ ៦) ។

ខ. បណ្តាមុខទំនិញផ្សេងទៀតក្រៅពីចំណុចទី ៣.ក ខាងលើដែលមានវេទយិតភាពខ្ពស់ និងអាចប៉ះពាល់ដល់សន្តិសុខសុវត្ថិភាពសាធារណៈដូចជា គ្រឿងសាស្ត្រាវុធ ជាតិផ្ទុះ សម្ភារៈបរិក្ខារយោធា គ្រឿងញៀន និងសារធាតុប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ។

គ. បណ្តាមុខទំនិញដែលត្រូវបានហាមឃាត់មិនឱ្យដឹកជញ្ជូនឆ្លងកាត់ដោយកិច្ចព្រមព្រៀងអន្តរជាតិនានា ក៏ដូចជាធម្មនុញ្ញសហប្រជាជាតិ ដែលអាចរួមមាន បណ្តាសត្វ និងរុក្ខជាតិព្រមទាំងបំណែកសត្វ និងរុក្ខជាតិដែលឈានទៅបាត់បង់ វត្ថុបុរាណ ឬសារធាតុនុយក្លេអែរជាដើម ។

ទទួលបានសេចក្តីណែនាំនេះ សូមអស់លោក លោកស្រី ដែលជាប្រធានសាខាការិយាល័យនិងទីស្នាក់ការគយ និងរដ្ឋាករពាក់ព័ន្ធទាំងអស់ ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា

**បណ្ឌិត.ប៉ែន_ស៊ីម៉ន**

**ចម្លងជូន** :
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
  "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្មកម្ពុជា
- ប្រតិបត្តិករសេវ្ទិធិគយបណ្តោះអាសន្ន
- ប្រតិបត្តិករកណ្តាគារគយមានដែនកំណត់
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្តតាមមុខការ
- ឯកសារ - កាលប្បវត្តិ

# ឧបសម្ព័ន្ធ

*នៃសេចក្តីណែនាំលេខ ១០៩០ គរ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨ របស់ទីចាត់ការគយ និងរដ្ឋាករ*

## ស្តីពីការអនុវត្ត នីតិវិធីនៃការឆ្លងកាត់គយ

## គម្រូត្រាឆ្លងកាត់

**ឆ្លងកាត់ TRANSIT**

- រថយន្តលេខ Vehicle N°: .................... Container N°: ....................
- សៀលលេខ Seal N°: ....................
- ការិ.ចេញដំណើរ Office of Departure .......... ការិ.គម្យដ្ឋាន Office of Destination ..........
- ត្រូវបង្ហាញការិយាល័យគយគម្យដ្ឋាន មុនម៉ោង 17:00 ថ្ងៃទី .......... ខែ .......... ឆ្នាំ 20
- ពម្រាយផ្លូវស្របច្បាប់ Legal Route ....................
- មន្ត្រីគយ Customs Officer: *(ហត្ថលេខា ត្រា ឈ្មោះ និងអត្តលេខ)*
- ថ្ងៃទី.......... ខែ.......... ឆ្នាំ 20..........

ទទឹងប្រវែង ៧៥ មិល្លីម៉ែត្រ

បណ្តោយប្រវែង ១២០ មិល្លីម៉ែត្រ

SPECIMEN

**ឆ្លងកាត់ TRANSIT**

- រថយន្តលេខ Vehicle N°: ភព 3A-000 Container N°: TTNU 9010112
- សៀលលេខ Seal N°: 00002
- ការិ.ចេញដំណើរ Office of Departure ប៊ាវិត ការិ.គម្យដ្ឋាន Office of Destination ផែស្ងួត xx
- ត្រូវបង្ហាញការិយាល័យគយគម្យដ្ឋាន មុនម៉ោង 17: 00 ថ្ងៃទី 28 ខែ តុលា ឆ្នាំ 2008
- ពម្រាយផ្លូវស្របច្បាប់ Legal Route ផ្លូវជាតិលេខ 1 - ផ្លូវលេខ 271 (ភ្នំពេញ) - ផ្លូវ វេងស្រេង (ភ្នំពេញ) - ផែស្ងួត xx
- មន្ត្រីគយ Customs Officer: ហត្ថលេខា និងត្រា: (នាមមន្ត្រីគយ)
- ថ្ងៃទី 27 ខែ តុលាឆ្នាំ 2008

អត្តលេខ XXXX